Cambodian



# ការរៀបចំឲ្យមាន ស្តង់ដារសិក្សាសំខាន់ចាំបាច់ រដ្ឋវិចតូរីយ៉ា

## ព័ត៌មានសំខាន់សំរាប់មាតាបិតាអំពីវិធីថ្មី ក្នុងការសិក្សារបស់សិស្ស និងស្តង់ដារ នៅតាមសាលារៀនរដ្ឋវិចតូរីយ៉ា

VICTORIAN CURRICULUM AND ASSESSMENT AUTHORITY

ស្តង់ដារសិក្សាសំខាន់ចាំបាច់នៃរដ្ឋវិចតូរីយ៉ា ផ្តល់នូវវិធីថ្មីមួយដល់កម្មវិធីសិក្សាចាប់ពីថ្នាក់ត្រៀម ទៅដល់ថ្នាក់ទី១០ សំរាប់សាលារៀនទាំងអស់នៅទូទាំងរដ្ឋវិចតូរីយ៉ា។ ស្តង់ដារទាំងនេះគូសបញ្ជាក់ប្រាប់អំពីអ្វីដែលសំខាន់សំរាប់សិស្សដើម្បីរៀនសូត្រ និងដើម្បីឲ្យទទួលបានការរីកចំរើនលូតលាស់នៅពេលដែលខ្លួនសិក្សានៅសាលារៀន។ ស្តង់ដារទាំងនេះក៏នឹងត្រូវបានតាក់តែងឡើង ដើម្បីលើកទឹកចិត្តឲ្យមានការយល់ដឹងយ៉ាងជ្រៅជ្រះអំពីចំណេះដឹង ជំនាញការ និងឥរិយាបទដែលសំខាន់ចាំបាច់ ហើយក៏នឹងត្រូវបានយកមកប្រើដើម្បីរៀបចំគំរោងសិក្សារបស់សិស្ស ដាក់ពិន្ទុដល់ការចំរើនលូតលាស់របស់សិស្ស និងធ្វើរបាយការណ៍សិក្សាទៅមាតាបិតា។

ស្តង់ដារទាំងនេះត្រូវបានរៀបចំឡើងក្រោយពីមានការស្រាវជ្រាវជាតិ និងអន្តរ:ជាតិធ្វើឡើងដោយអាជ្ញាធរកម្មវិធិសិក្សា និងការដាក់ពិន្ទុនៃរដ្ឋវិចតូរីយ៉ា (VCAA)។ ការពិភាក្សាមួយចំនួនត្រូវបានធ្វើឡើងជាមួយគ្រូបង្រៀននៅរដ្ឋវិចតូរីយ៉ា ហើយការពិគ្រោះនានាបានកើតមានឡើងជាមួយក្រុមសិក្សាអប់រំ និងសហគមន៍ទូទៅ។ អ្នកទាំងនេះមានរួមទាំងក្រុមអ្នកតំណាងមាតាបិតានៅតាមតំបន់ជុំវិញក្រុង និងនៅតានតំបន់ភូមិភាគរដ្ឋវិចតូរីយ៉ា។ ជាផ្នែកនៃការពិគ្រោះនេះ VCAA បានទទួលការឆ្លើយតប និងសំណើលើសពី១០០០។

## សេចក្តីត្រូវការឲ្យមានវិធីថ្មី

ក្តីរំពឹងរបស់យុវវ័យកំពុងមានការផ្លាស់ប្តូរ។ រដ្ឋវិចតូរីយ៉ាមានសាលារៀនល្អកម្មវិធីល្អ និងគ្រូបង្រៀនល្អ ក៏ប៉ុន្តែវាជាការសំខាន់ដែលត្រូវបន្តស្វែងរកវិធីសិក្សារបស់សិស្ស និងអ្វីដែលសិស្សត្រូវការដើម្បីឲ្យខ្លួនបានក្លាយទៅជាអ្នករៀនសូត្រប្រកបដោយជោគជ័យ។

ស្តង់ដារទាំងនេះមានគោលបំណងឆ្លងឲ្យផុតឧបសគ្គទាំងឡាយដើម្បីត្រៀមខ្លួនយុវវ័យ សំរាប់ពិភពលោកមួយដែលឲ្យតម្លៃយ៉ាងខ្ពស់ដល់ចំណេះវិជ្ជាដែលតែងមានការផ្លាស់ប្តូរជានិច្ច ជាពិភពលោកមួយដែលផ្នែកការងារសង្គម សហគមន៍ និងទំនាក់ទំនងផ្ទាល់ខ្លួនត្រូវស្ថិតនៅក្រោមសម្ពាធកាន់តែស្មុគស្មាញឡើង។

យុវវ័យត្រូវការមានចំណេះចេះដឹងឲ្យបានទូលំទូលាយ និងភាពស្ទាត់ជំនាញផ្នែកសង្គម ផ្ទាល់ខ្លួន និងការគិតគូរដើម្បីឲ្យបានជោគជ័យ។ ស្តង់ដារទាំងនេះនឹងអាចឲ្យយុវវ័យចំរើនលូតលាស់តាមរយ:ការសិក្សារបស់ខ្លួន ហើយត្រៀមខ្លួនលក្ខណ:ពួកគេសំរាប់ឆ្នាំចុងក្រោយនៃការសិក្សារបស់គេក្នុង:

- វិញ្ញាបនបត្រសិក្សារដ្ឋវិចតូរីយ៉ា (VCE)
- វិញ្ញាបនបត្រសិក្សាដោយការអនុវត្ត (VCAL)

សិស្សក៏អាចជ្រើសរើសយកកម្មវិធីសិក្សា និងហ្វឹកហ្វឺនផ្នែកវិជ្ជាជីវ: (VET) មកជាផ្នែកនៃការសិក្សា VCE ឬ VCAL ផងដែរ។

## តើអ្វីខ្លះស្ថិតនៅដដែល? តើអ្វីខ្លះកំពុងផ្លាស់ប្តូរ?

សិស្សនឹងនៅតែបន្តទទួលបានចំណេះ និងការយល់ដឹងតាមមុខវិជ្ជាដែលមានជារហូតមកដូចជាភាសាអង់គ្លេស វិទ្យាសាស្ត្រ គណិតសាស្ត្រ មនុស្សសាស្ត្រ ភាសា និងសិល្ប:វិទ្យាទូទៅ។ ទោះបីយ៉ាងនេះក្តី វិធីថ្មីនេះតភ្ជាប់ឲ្យរឹតតែស្អិតរមួតថែមទៀតនូវមុខវិជ្ជាដែលមានជារហូតមកទាំងនោះ ជាមួយនឹងវិស័យសិក្សាសំខាន់ៗដទៃទៀតទាក់ទងនឹងការលូតលាស់ផ្នែករូបកាយផ្ទាល់ខ្លួន និងសង្គម ព្រមទាំងសមត្ថភាពក្នុងការអនុវត្តចំណេះដឹងនៅក្នុងជីវិតរស់នៅទៀតផង។ ជាផ្នែកនៃវិធីថ្មីនេះ ស្តង់ដារទាំងនេះក៏ត្រូវបានរៀបចំឡើងក្នុងវិស័យមួយចំនួនដូចជាការបង្កើតទំនាក់ទំនងក្នុងសង្គម ការបង្កើតខាងជំនាញការគិតគូរ និងការប្រាស្រ័យទាក់ទងគ្នាផងដែរ។



# ព័ត៌មានសំខាន់សំរាប់មាតា



## ធុងបីនៃការសិក្សា

ស្តង់ដារសិក្សាសំខាន់ចាំបាច់នៃរដ្ឋវិចតូរីយ៉ា ត្រូវបានរៀបចំឡើងនៅក្នុងធុង ឬផ្នែកសំខាន់បីដែលមាន:

- ចំណេះ និងការយល់ដឹងចេញក្នុងមុខវិជ្ជាសំខាន់ដូចជាភាសាអង់គ្លេស វិទ្យាសាស្ត្រ គណិតសាស្ត្រ មនុស្សសាស្ត្រ ភាសា និងសិល្ប: វិទ្យាទូទៅ។
- ជំនាញការខាងផ្លូវកាយ ផ្ទាល់ខ្លួន និងសង្គមមានដែលមានដូចជាធ្វើឲ្យខ្លួនមានសកម្មភាព និងសុខភាពល្អ បង្កើតការទុកចិត្តលើខ្លួនឯង ចាត់ចែងការសិក្សាផ្ទាល់ខ្លួន និងធ្វើការជាមួយអ្នកដទៃ។
- ជំនាញការសំខាន់ចាំបាច់ដទៃទៀត ដែលអនុវត្តនៅគ្រប់ផ្នែកកម្មវិធីសិក្សាដូចជាការគិតពិចារណា ការតាក់តែងរៀបចំ ការធ្វើចំណោទ ការប្រាស្រ័យទាក់ទង និងការប្រើបច្ចេកវិទ្យាព័ត៌មាន និងប្រាស្រ័យទាក់ទងគ្នា។

ផ្នែកទាំងនេះសុទ្ធតែសំខាន់ទាំងអស់ សំរាប់លូតលាស់របស់យុវវ័យដែលពូកែគ្រប់មុខ ហើយមានជំនឿចិត្តលើខ្លួនឯង។ ផ្នែកទាំងនេះជាញឹកញយបានក្លាយជាបទពិសោធន៍នៅសាលាសំរាប់យុវវ័យ។ ក៏ប៉ុន្តែផ្នែកទាំងនេះមិនត្រូវបានតភ្ជាប់ឲ្យបានស្អិតរមួតជាមួយផ្នែកមុខវិជ្ជាដែលមានជារហូតនោះទេ។ ការដែលយកផ្នែកទាំងនេះមកដាក់បញ្ចូលរួមគ្នា ផ្តល់នូវសារ:សំខាន់ទៅលើតម្លៃ និងភាពទាក់ទងរបស់វានៅក្នុងការសិក្សារបស់សិស្ស។

## ស្តង់ការដែលបានកើនឡើងក្នុងអម្លុងពេលមួយរយ:កាល

រដ្ឋវិចតូរីយ៉ាមានស្តង់ដារកម្មវិធីសិក្សា និងការដាក់ពិន្ទុនៅតាមសាលារៀនជាច្រើនឆ្នាំមកហើយ។ កន្លងមកមានទស្សន:មុិងម៉ាត់ថាមានពេលខ្វះ អ្វីដែលគេបង្ហាត់បង្រៀននៅតាមសាលារៀនធ្វើឲ្យមានកម្មវិធីសិក្សាច្រើនពេក។ ស្តង់ដារថ្មីផ្តល់ពេលវេលាបន្ថែមទៀតដល់សាលារៀន ដើម្បីផ្តង់ទៅលើអាទិភាពខុសៗគ្នា ដោយអាស្រ័យទៅលើអាយុកុមារ និងដំណាក់កាលនៃការសិក្សារបស់ពួកគេ។

ស្តង់ដារថ្មីបញ្ជាក់នូវអ្វីដែលសំខាន់ចាំបាច់សំរាប់ឲ្យសិស្សចេះ ហើយឲ្យអាចធ្វើបាន នៅពេលដែលគេឆ្លងកាត់ដំណាក់កាលនីមួយៗក្នុងការសិក្សារបស់ពួកគេ។ ស្តង់ដារទាំងនេះមានភាពលំបាកទៅៗនៅពេលដែលសិស្សចំរើនលូតលាស់ រហូតដល់ចុងបញ្ចប់នៃថ្នាក់ទី១០។

តាមស្តង់ដារថ្មីទាំងនេះ នៅបណ្តាឆ្នាំដំបូង (ពីថ្នាក់ត្រៀម ទៅដល់ថ្នាក់ទី៤) នឹងបន្តមានការយកចិត្តទុកដាក់ទៅលើការចេះអាន និងសរសេរ និងការគិតលេខ។ លើសពីនេះទៀតនឹងមានការយកចិត្តទុកដាក់កាន់តែខ្លាំងឡើងថែមទៀតលើសុខភាព ការអប់រំផ្នែករាងកាយ និងការពង្រីក ជំនាញទំនាក់ទំនងរវាងមនុស្ស និងមនុស្ស។



នៅពេលដែលសិស្សឡើងពីថ្នាក់មួយ ទៅថ្នាក់មួយក្នុងការសិក្សាថ្នាក់បឋមសាលា នឹងមានផ្នែកបន្ថែមទៀតដកស្រង់ពីធុងទាំងបីដើម្បីដាក់បញ្ចូលទៅក្នុងកម្មវិធីរបស់សិស្ស ផ្នែកទាំងនោះមានដូចជាវិទ្យាសាស្ត្រ បច្ចេកវិទ្យាព័ត៌មានប្រាស្រ័យទាក់ទងគ្នា និងប្រជាពលរដ្ឋ និងសញ្ជាតិ។ នៅពេលដែលសាលាដាក់បញ្ចូលផ្នែកថ្មីៗទាំងនេះទៅក្នុងកម្មវិធីរបស់សិស្សនោះ សាលានឹងបន្តយកចិត្តទុកដាក់ ហើយធ្វើឲ្យបានប្រសើរឡើងថែមទៀតលើផ្នែកសំខាន់ៗចាំបាច់ដែលមានការចេះអានចេះសរសេរ និងការគិតលេខ។

នៅទីបញ្ចប់នៃសាលាបឋមសិក្សា ស្តង់ដារសិក្សាសំខាន់ចាំបាច់នៃរដ្ឋវិចតូរីយ៉ា នឹងផ្តល់នូវស្ពានឆ្លងយ៉ាងច្បាស់លាស់ទៅកាន់សាលាមធ្យមសិក្សា។ ស្តង់ដារទាំងនេះផ្តល់នូវមូលដ្ឋានដ៏រឹងមាំ សំរាប់ឲ្យសិស្សអាចឆ្លងពីកម្រិតបឋមសិក្សា ទៅកម្រិតមធ្យមសិក្សាបាន។ គ្រូបង្រៀននៅសាលាបឋមសិក្សា និងមធ្យមសិក្សា ក៏នឹងបន្តបង្កើតឲ្យមានមូលដ្ឋានរួមមួយ ដោយមានការ



ពិភាក្សារវាងគ្រូមកពីសាលាទាំងពីរអំពីចំណុចខ្លាំង និងចំណុចខ្សោយរបស់សិស្សម្នាក់ៗ។

នៅសាលាមធ្យមសិក្សា ស្តង់ការនឹងបន្តដកស្រង់ចេញពីផ្ទុងទាំងបី ហើយនឹងឆ្លុះបញ្ចាំងអំពីតម្រូវការក្នុងការសិក្សាពេលបច្ចុប្បន្ននេះ នៃការសិក្សាអប់រំរបស់សិស្ស។ នៅពេលចូលមកដល់ថ្នាក់ទី៩ និងទី១០ ស្តង់ដារទាំងនេះទទួលស្គាល់ថាសិស្សកំពុងមានការលូតលាស់ជាងមុនខាងផ្នែកគំនិត និងចំណាប់អារម្មណ៍ផ្ទាល់ខ្លួន ហើយកំពុងស្វែងរកទំនាក់ទំនងឲ្យបានជ្រៅជាងមុនរវាងការសិក្សា និងផ្លូវទៅថ្ងៃអនាគតរបស់ពួកគេ។

## តើស្តង់ដារទាំងនេះនឹងដាក់បញ្ចូលនៅពេលណា?

- ស្តង់ដារទាំងនេះនឹងត្រូវដាក់បញ្ចូលជាលំដាប់ នៅគ្រប់ទាំងសាលារៀនរដ្ឋវិចតូរីយ៉ាចាប់ពីខែមករា ឆ្នាំ២០០៦ទៅ ដោយចាប់ផ្តើមជាមួយមុខវិជ្ជា ភាសាអង់គ្លេស និងគណិតវិទ្យា។ នៅក្នុងអម្លុងឆ្នាំ២០០៥ គ្រប់ទាំងសាលារៀននឹងរំពឹងគិតពីមធ្យោបាយថ្មីៗនៃការតភ្ជាប់ការសិក្សាក្នុងកម្មវិធីសិក្សារបស់គេ ហើយចាប់ផ្តើមធ្វើការផ្លាស់ប្តូរ ដើម្បីធានាឲ្យបានថាគេអាចមានកម្មវិធីរួចជាស្រេចដើម្បីអនុវត្តស្តង់ដារទាំងនេះ។
- ក្នុងកាលដែលសាលារៀនទទួលយកស្តង់ដារថ្មីទាំងនេះជាលំដាប់ សាលារៀនទាំងនោះគេនឹងតាមដានគោលការណ៍នៃការសិក្សា និងការបង្រៀន ហើយធ្វើឲ្យកាន់តែល្អឡើងនូវរបៀបដាក់ពិន្ទុ និងការធ្វើរបាយការណ៍។ VCAA និងក្រសួងអប់រំ និងហ្វឹកហ្វឺននឹងបន្តផ្តល់នូវព័ត៌មានដល់សាលារៀន និងមាតាបិតានៅក្នុងអម្លុងពេលនៃការអនុវត្តស្តង់ដារទាំងនេះ។

## តើលោកអ្នកអាចទទួលយកព័ត៌មានបន្ថែមទៀតដោយរបៀបណា?

- សូមបើកមើលគេហទំព័រស្តង់ដារ នៅត្រង់កន្លែង http://vels.vcaa.vic.edu.au
- ទូរស័ព្ទទៅ VCAA លេខ (03) 9651 4544 ឬ 1800 134 197 (អ្នកទូរស័ព្ទពីតំបន់ជនបទ)
- ដើម្បីទទួលយកព័ត៌មានស្តីអំពី Blueprint (ផែនការ) សំរាប់សាលារៀនរដ្ឋ សូមបើកមើលគេហទំព័រ www.sofweb.vic.edu.au/blueprint/
- ទាក់ទងជាមួយសាលារៀនរបស់កូនលោកអ្នក។

## តើលោកអ្នកអាចចូលរួមដោយវិធីណា?

- សាកសួរក្រុមប្រឹក្សាសាលារៀនរបស់លោកអ្នក ឬនាយកសាលារបស់លោកអ្នកអំពីវិធីដែលសាលារៀនរបស់លោកអ្នកកំពុងយកមកអនុវត្តដើម្បីគាំទ្រការផ្លាស់ប្តូរដ៏សំខាន់នេះ។
- សាកសួរសាលារៀនរបស់លោកអ្នកថាតើអ្វីខ្លះស្ថិតនៅដដែល និងអ្វីខ្លះនឹងផ្លាស់ប្តូរដែលជាលទ្ធផលនៃការដាក់បញ្ចូលស្តង់ដារទាំងនេះ។
- ចូលរួមនៅក្នុងកិច្ចប្រជុំផ្តល់ព័ត៌មានអំពីស្តង់ដារសិក្សាសំខាន់ចាំបាច់នៃរដ្ឋវិចតូរីយ៉ា សាកសួរសំនួរ និងធ្វើការចូលរួមផ្តល់មតិ។

នេះគឺជាឱកាសដ៏ល្អសំរាប់យើងគ្រប់គ្នា ដើម្បីយកចិត្តទុកដាក់លើយុវវ័យ និងវិធីសិក្សារបស់ពួកគេ។

© VCAA 2005

Published by
VICTORIAN CURRICULUM AND ASSESSMENT AUTHORITY
41 St Andrews Place East Melbourne Victoria 3002 Australia
TELEPHONE +61 3 9651 4300 FACSIMILE +61 3 9651 4324
EMAIL vcaa@edumail.vic.gov.au
WEB www.vcaa.vic.edu.au

Victoria
The Place To Be